ព័ត៌មានសហគមន៍នេសាទនៅតំបន់ឆ្នេរ

# សហគមន៍នេសាទអូរក្រសារ ខេត្តកែប (២០១៩)

## ស្ថានភាពទូទៅ

សហគមន៍នេសាទអូរក្រសារមានទីតាំងស្ថិតនៅភូមិអូរក្រសារ ឃុំអូរក្រសារ ស្រុកដំណាក់ចង្អើរ ខេត្តកែប។ សហគមន៍នេសាទនេះមានផ្ទៃដីទំហំ៤៤៦ហិកតា ក្នុងនោះមានកន្លែងអភិរក្សកូនក្តាមថ្មមានទំហំ៥០ហិកតា តំបន់ព្រៃកោងកាងមានទំហំប្រហែល៤៦,៥៩ហិកតា។ សហគមន៍នេសាទនេះមានសមាជិកសរុប២៣៦នាក់ (ស្រី៤៥នាក់) និងមានសមាជិកគណៈកម្មការសហគមន៍នេសាទចំនួន១១នាក់ (ស្រី០១នាក់)។



**កាលបរិច្ឆេទបង្កើតសហគមន៍៖** ឆ្នាំ ២០០៨

**ការចុះបញ្ជី៖** បានចុះបញ្ជីទទួលស្គាល់ជាផ្លូវការពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នាថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៣។

## ការគាំទ្រពីអ្នកពាក់ព័ន្ធ

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- រដ្ឋបាលជលផល
- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកែប
- ខណ្ឌរដ្ឋបាលជលផលខេត្តកែប
- មន្ទីរបរិស្ថានខេត្តកែប
- មន្ទីរទេសចរណ៍ខេត្តកែប
- អាជ្ញាធរមូលដ្ឋាន

## ដៃគូអភិវឌ្ឍន៍/អង្គការមិនមែនរដ្ឋាភិបាល

- មិនមានព័ត៌មាន

## ព័ត៌មានទំនាក់ទំនង

**ទូរស័ព្ទ៖** (+៨៥៥) ៨១ ៨២២ ០៦៣
(+៨៥៥) ៩៦ ២៦៣ ០៩ ១១

**អាសយដ្ឋាន៖** ភូមិអូរក្រសារ ឃុំអូរក្រសារ ស្រុកដំណាក់ចង្អើរ ខេត្តកែប។

**ឯកសារយោង៖**

- លក្ខន្តិកៈសហគមន៍នេសាទអូរក្រសារ
- បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទអូរក្រសារ
- ផែនទីសហគមន៍នេសាទអូរក្រសារ
- កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍អូរក្រសារ
- ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍អូរក្រសារ
- ប្រកាសលេខ១៤០ ស្តីពីការចុះបញ្ជីសហគមន៍នេសាទ ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៣

## មុខរបរចិញ្ចឹមជីវិត

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍រួមមាន៖

- ធ្វើនេសាទចំនួន២៣៦នាក់
- ធ្វើស្រែ និងចិញ្ចឹមសត្វចំនួន១៦០នាក់
- ដាំបន្លែចំនួន១០នាក់
- លក់ដូរចំនួន៣០នាក់
- អ្នកកែច្នៃគីចំនួន០១នាក់

## ជនជាតិ និងសាសនា

**ជនជាតិ៖** មិនមានព័ត៌មាន

**សាសនា៖** មិនមានព័ត៌មាន

## ប្រជាសាស្ត្រ

ចំនួនប្រជាពលរដ្ឋសរុបក្នុងសហគមន៍៖ ៤.១៣៩នាក់ (ស្រី២.១២១នាក់)

**អ្នកនេសាទ**

ចំនួនអ្នកនេសាទជាសមាជិកសហគមន៍សរុប៖ ២៣៦នាក់ (ស្រី១៣៧នាក់)

ចំនួនអ្នកនេសាទមិនមែនជាសមាជិកសហគមន៍ដែលរស់នៅក្នុងសហគមន៍សរុប៖ ១០៥នាក់ (ស្រី៧៦នាក់)

ចំនួនអ្នកនេសាទដែលមកពីខាងក្រៅសហគមន៍សរុប៖ ៣៥គ្រួសារ/ឆ្នាំ



## ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ត្រូវបានរៀបចំឡើងដោយអនុលោមតាមប្រការ២៣ នៃប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍នេសាទរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយផ្អែកលើមូលដ្ឋានព័ត៌មានពាក់ព័ន្ធនឹងស្ថានភាពសេដ្ឋកិច្ចសង្គមរបស់ប្រជាពលរដ្ឋ ការនេសាទ និងកសិកម្ម លក្ខណៈនៃដែននេសាទ សកម្មភាពពាក់ព័ន្ធនឹងការនេសាទ និងបញ្ហាដែលកើតមាននៅក្នុងសហគមន៍។ សហគមន៍នេសាទអូរក្រសារបានរៀបចំផែនការបីឆ្នាំសម្រាប់ឆ្នាំ២០១៩-២០២២។ ផែនការនេះបានបង្ហាញនូវទស្សនៈវិស័យរយៈពេលបីឆ្នាំ ដែលអាចរួមចំណែកក្នុងការធានាបាននូវការអភិវឌ្ឍសហគមន៍ប្រកបដោយចីរភាព។

នៅក្នុងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ មានផែនការការប្រើប្រាស់ឧបករណ៍នេសាទ ការចុះល្បាត ការកែលំអកន្លែងនេសាទ ការរៀបចំកន្លែងអភិរក្ស ការគ្រប់គ្រងព្រៃកោងកាង ការអភិវឌ្ឍវារីវប្បកម្ម ការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍ ការផ្សព្វផ្សាយពីច្បាប់ជលផលនិងលិខិតបទដ្ឋានពាក់ព័ន្ធ ការបង្កើតស្នាក់ការនិងបណ្ណាល័យសហគមន៍នេសាទ ព្រមទាំងផែនការទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍។

**ផែនការថវិកា៖** គណៈកម្មការសហគមន៍នេសាទអូរក្រសារ កំពុងស្វែងរកប្រាក់ចំណូលពីប្រភពផ្សេងៗដូចជាភាគទានពីសមាជិកសហគមន៍ អង្គការដៃគូរអភិវឌ្ឍន៍ សប្បុរសជន ក្រុមប្រឹក្សាសង្កាត់ និងការធ្វើទស្សនៈកិច្ចរបស់ភ្ញៀវមកក្នុងសហគមន៍នេសាទ។

## តំបន់ការពារ និងកន្លែងគ្រប់គ្រងជលផល

មិនមានព័ត៌មាន

## កន្លែងគ្រប់គ្រងស្មៅសមុទ្រ និងព្រៃកោងកាងរបស់សហគមន៍នេសាទ

សហគមន៍នេសាទអូរក្រសារបានសម្រេចបង្កើតកន្លែងគ្រប់គ្រងចំនួន០២កន្លែង ក្នុងនោះមានកន្លែងគ្រប់គ្រងកូនក្តាមថ្មមានទំហំប្រមាណ៥០ហិកតា និងតំបន់គ្រប់គ្រងព្រៃកោងកាងមានទំហំប្រមាណ៩៦,៤១ហិកតា។



## ធនធានជលផល

មច្ឆជាតិ៖ ត្រី៣៣ប្រភេទ វារីសត្វ១៧ប្រភេទ និងរុក្ខជាតិព្រៃកោងកាង និងវារីរុក្ខជាតិសមុទ្រ ១៥ប្រភេទ។
ផលនេសាទ៖ ត្រីក្នុងមួយឆ្នាំរកបាន៨៤០គីឡូក្រាមក្នុងមួយគ្រួសារ។

## បញ្ហាប្រឈម

- ការនេសាទខុសច្បាប់
- អនាធិបតេយ្យ និងជម្លោះដែននេសាទ

ផលិតដោយ

ជំនួយរបស់សហភាពអឺរ៉ុប

ឯកសារនេះរចនាដោយអង្គការទិន្នន័យអំពីការអភិវឌ្ឍ (អូឌីស៊ី) សហការជាមួយរដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មជ្ឈមណ្ឌលអភិវឌ្ឍន៍កុមារនិងស្ត្រីនៅកម្ពុជា និងអង្គការអាកសិនអេតដោយគាំទ្រថវិកាពីសហភាពអឺរ៉ុប។ទិន្នន័យនិងព័ត៌មាននៅលើផ្ទាំងព័ត៌មានទិន្នន័យសហគមន៍នេសាទនៅតំបន់ឆ្នេរដកស្រង់ចេញពីឯកសារយោងដែលមានស្រាប់ និងមិនមែនជាការឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុបឡើយ។